**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកែសម្រួលមាត្រា៧ មាត្រា១៣ និងមាត្រា១៩ នៃអនុក្រឹត្យលេខ ១២អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ១២អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ .-**

មាត្រា៧ មាត្រា១៣ និងមាត្រា១៩ នៃអនុក្រឹត្យលេខ១១២អនក្រ.បក ចុះថ្ងៃ ទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា៧ .-ថ្មី**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៥ សម្រាប់កងទ័ពជើងគោកដែលមានរូបភាពនិងម៉ូដដូចខាងក្រោម៖

**១-ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍**

គំរូឯកសណ្ឋានលេខ៥ មានពីរប្រភេទ ប៉ាភ៉ាក្រឡាធំ និងប៉ាភ៉ាក្រឡាតូច។

**១-១-ឯកសណ្ឋានប៉ាភ៉ាក្រឡាធំ**

-អាវដៃវែង កបើកថ្នេរឱបមានប៉ូលស្មា ហោប៉ៅបួនដេរយោគ មានគម្របរាងចតុកោណកែង ឡេវជ័រពណ៌ត្រែអ៊ី មានអង្កត់ផ្ចិត២០ម.ម ដាក់បង្កប់ទាំងអស់ ចុងដៃអាវរាងបំពង់មានក្រវ៉ាត់

-ខោជើងវែង ថ្នេរឱបហោប៉ៅក្រោយពីរដេរបង្កប់មានគម្របរាងចតុកោណកែង នៅចំហៀងតាមថ្នេរខោមានហោប៉ៅបត្លិត ប៉ានជង្គង់ ប៉ានគូទ នៅសងខាងភ្លៅមានហោប៉ៅយោគធំពីរ។ នៅចំកណ្តាលហោប៉ៅមានបត់ផ្នត់ពីរជាន់ គម្របរាងចតុកោណកែង ហោប៉ៅនីមួយៗមានឡេវជ័រពីរគ្រាប់ ពណ៌ត្រែអ៊ីមានអង្កត់ផ្ចិត២០ម.ម ហើយដាក់បង្កប់ទាំងអស់ ជើងខោចងខ្សែ ឬខ្សែយឺត

-មួកដែក ឬមួកហ្សិរកឺប៉ាភ៉ា នៅលើហាមមួកហ្សិរកឺមានប៉ាក់ក្បាច់ភ្ញីទេសអំពីអំបោះពណ៌មាសដល់ចុងហាមមួក(ចំកណ្តាលមានកម្ពស់៣២ម.ម)។ នៅផ្នែកខាងមុខមានប៉ាក់ភ្ជាប់រូបព្រះសង្ហារពីអំបោះពណ៌មាសកម្ពស់៥ស.ម ទទឹង៤ស.ម យកតាមសញ្ញាជាតិ

-មួកបេរ៉េពណ៌ត្រែអ៊ី ប៉ាក់រូបព្រះសង្ហារពណ៌មាស (ទ័ពការពារព្រំដែនពណ៌បៃតង មជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសំអាតមីន និងកាកសំណល់សង្គ្រាមពណ៌ខៀវដូចមួកអង្គការសហប្រជាជាតិ)

-ស្បែកជើងកវែងប៉ាភ៉ា ឬពណ៌ខ្មៅ ខ្សែក្រវ៉ាត់តូចពណ៌ត្រែអ៊ី ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្រោមជើងពណ៌ត្រែអ៊ី និងខ្សែសាំង ទៀរុងពណ៌ត្រែអ៊ី។

**១-២-ឯកសណ្ឋានប៉ាភ៉ាក្រឡាតូចសម្រាប់ទ័ពពិសេសឆត្រយោង**

-អាវដៃវែង កបើក ថ្នេរឱបមានប៉ូលស្មា ហោប៉ៅពីរខាងលើ ដេរយោគមានគម្របរាងចតុកោណកែង ឡេវជ័រពណ៌ត្រែអ៊ី មានអង្កត់ផ្ចិត២០ម.ម ដាក់បង្កប់ទាំងអស់ ចុងដៃអាវរាងបំពង់មានក្រវ៉ាត់បិទស្អិត

-ខោម៉ូដដូចឯកសណ្ឋានប៉ាភ៉ាក្រឡាធំ

-មួកដែក ឬមួកហ្សិរកឺ ដូចមួកឯកសណ្ឋានប៉ាភ៉ាក្រឡាធំ

-មួកបេរ៉េពណ៌ក្រហម ប៉ាក់រូបព្រះសង្ហារពណ៌មាស

-ស្បែកជើងកវែងប៉ាក់ ឬពណ៌ខ្មៅ ខ្សែក្រវ៉ាត់តូចពណ៌គ្រែអ៊ី ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្រោមជើងពណ៌គ្រែអ៊ី និងខ្សែសាំងទៀវងពណ៌គ្រែអ៊ី។

**២-ឯកសណ្ឋានថ្នាក់វរសេនីយ៍**

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ៊្សែកកីមានក្បាច់ភ្ញីទេសនៅហាមមួកទុកចន្លោះ ៥ស.ម ពីជើងមួក។

**៣-ឯកសណ្ឋានថ្នាក់អនុសេនីយ៍**

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ៊្សែកកីមានឆ្នូតពណ៌មាសលើគែមហាមមួក។

**៤-ឯកសណ្ឋានថ្នាក់នាយទាហានរង និងពលទាហាន**

រូបភាព ម៉ូដ ឯកសណ្ឋានដូចថ្នាក់ឧត្តមសេនីយ៍ តែខុសគ្នាត្រង់មួកហ៊្សែកកីគ្មានក្បាច់ភ្ញីទេស ឬឆ្នូតអ្វីទាំងអស់នៅលើហាមមួក។

រូបភាព ឯកសណ្ឋានប្រយុទ្ធទ័ពពិសេសឆត្រយោងមានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា១៣ .-ថ្មី**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៤ សម្រាប់កងទ័ពជើងទឹកដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

**១-ឯកសណ្ឋានថ្នាក់ឧត្តមនាវី**

-អាវដៃខ្លីពណ៌ស កឧប មានប៉ូលស្មាទាំងសងខាងកាត់ស្រុងវែងដាក់ក្នុងខោ មានហោប៉ៅពីរដេរបង្កប់ចំកណ្ដាលដេរបត់ផ្នត់មួយមានគម្របរាងស្លឹកពោធិ៍ ឡេវធម្មតាពណ៌ស

-ខោជើងវែងពណ៌ស កាត់ម៉ូដដូចឯកសណ្ឋានលេខ៣

-មួកហ៊្សែកកីពណ៌ទឹកប៊ិកចាស់តាមលំដាប់ថ្នាក់ដូចកងទ័ពជើងគោក

-ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស ស្បែកជើងស្បែក កខ្លីពណ៌ស ចងខ្សែ និងស្រោមជើងពណ៌ស។

**២-ឯកសណ្ឋានថ្នាក់វរនាវី** ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី។

**៣-ឯកសណ្ឋានថ្នាក់អនុនាវី** ដូចឯកសណ្ឋានថ្នាក់ឧត្តមនាវី។

ចំពោះនារី អាវដូចបុរសតែកាត់តាមរាងដងខ្លួន ខោជើងវែងពណ៌ស ឬសំពត់ហ្សីបពណ៌សក្រោមជង្គង់។

**៤-ឯកសណ្ឋានថ្នាក់នាយនាវីរង និងពលនាវី**

-អាវការងារដៃវែង ពណ៌ស កអាវទម្លាក់មកក្រោមរាងជាកន្សែងវែង ប្រវែង២៥ស.ម ជុំវិញកអាវមាន ឆ្នូតពពណ៌ខៀវ ឆ្នូតនីមួយៗមានទំហំ៨ម.ម

-ខោជើងវែងពណ៌ស ស្បែកជើងស្បែក កខ្លីពណ៌សចងខ្សែ ស្រោមជើងពណ៌ស ខ្សែក្រវ៉ាត់ពណ៌ស ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស

-មួកម៉ាតឺឡូពណ៌ស ជើងមួកពណ៌ខៀវ លើជើងមួកមានសរសេរអក្សរពណ៌សថា **កងទ័ពជើងទឹក** កម្ពស់អក្សរ១៥ម.ម។ ជើងមួកខាងក្រោយឆែក មានខ្សែពីរសម្រាប់ចងនៅកន្ទុយខ្សែមានរាងកន្ទុយត្រី។

រូបភាពមួកហ៊្សេកកី មានគំរូដូចក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា១៩ .-ថ្មី**

ត្រូវបានរៀបចំឯកសណ្ឋានលេខ៣ សម្រាប់កងទ័ពជើងអាកាសដែលមានរូបភាព និងម៉ូដដូចខាងក្រោម៖

**១-ឯកសណ្ឋានថ្នាក់ឧត្តមសេនីយ៍**

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់ឧត្តមសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ខៀវផ្ទៃមេឃ

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរស តែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

**២-ឯកសណ្ឋានថ្នាក់វរសេនីយ៍**

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់វរសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ខៀវផ្ទៃមេឃ

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរស តែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

**៣-ឯកសណ្ឋានថ្នាក់អនុសេនីយ៍**

-អាវ ខោ មួកកាស្កេតពណ៌ខៀវទឹកប៊ិក កាត់ម៉ូដដូចថ្នាក់អនុសេនីយ៍កងទ័ពជើងគោក

-អាវយឺតក្នុងដៃខ្លីពណ៌ខៀវផ្ទៃមេឃ

-ស្បែកជើងស្បែក កខ្លីពណ៌ខ្មៅចងខ្សែ ខ្សែក្រវ៉ាត់ពណ៌ខៀវទឹកប៊ិក ក្បាលខ្សែក្រវ៉ាត់ធ្វើពីលោហធាតុលាតពណ៌មាស។

ចំពោះនារី អាវមានគំរូដូចបុរស តែកាត់តាមរាងដងខ្លួន និងសំពត់ហ្ស៊ីបក្រោមជង្គង់ពណ៌ខៀវទឹកប៊ិក។

សម្រាប់នាយទាហានរងនិងពលទាហាន នៅពេលបំពេញបេសកកម្មក្រៅប្រទេស ឬក្នុងពិធីការជាតិធំៗអាចមានឯកសណ្ឋានលេខ៣ដែរ ហើយឯកសណ្ឋាននោះដូចគ្នាថ្នាក់អនុសេនីយ៍ តែមួកកាស្កេតនៅហាមមួកគ្មានក្បាច់ភ្ញីទេស ឬឆ្នូតអ្វីទាំងអស់។

**មាត្រាពីរ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។/

**មាត្រាបី .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៩ កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមឡាយហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រាបី
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ២៧១អនក្រ.បកចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៩

ស្តីពីការកែសម្រួលមាត្រា៧ មាត្រា១៣ និងមាត្រា១៩ នៃអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីឯកសណ្ឋាន ស្លាកសញ្ញា និងទង់ជ័យនៃកងយោធពលខេមរភូមិន្ទ

## ១-មួកហ៊ីប្រកកកាបោះ



ឧត្តមនាវី វរនាវី អនុនាវី នាយទាហានរង និងពលទាហាន

## ២-ឯកសណ្ឋានប្រយុទ្ធប៉ារ៉ាក្រឡាតូច សម្រាប់ទ័ពពិសេសឆត្រយោង

